# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្វាសនៅកោះនរា
# ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៨

*ឲ្យយើងរស់នៅនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ*

អត្ថបទទី១៖ ទក ៤,១-២.៦-៨
អត្ថបទទី២៖ យក ២,១៧-១៨.២១ខ-២២.២៧
ដំណឹងល្អ៖ មក ៧,១-៨.១៤-១៥.២១-២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះមានគេឆ្ងល់ ដោយសារសាវ័ករបស់ព្រះយេស៊ូមុនហូបបាញគេមិនលាងដៃ ព្រះយេស៊ូចង់បំភ្លឺយើងអំពីជីវិតដែលយើងទទួលពីព្រះយេស៊ូផ្ទាល់។ ថ្ងៃនេះ យើងមានបងប្អូនមួយចំនួនទទួលព្រះកាយជាលើកទីមួយ នៅពេលយើងហែទទួលព្រះកាយក្នុងអភិបូជាគឺព្រះយេស៊ូផ្ទាល់ដែលចូលនៅក្នុងខ្លួនរបស់យើង។ នៅពេលយើងបានទទួលព្រះកាយ យើងនិងព្រះយេស៊ូទៅជាតែមួយ ព្រះយេស៊ូចូលនៅក្នុងខ្លួនយើងដើម្បីឲ្យយើងទទួលជីវិតពីព្រះយេស៊ូ។ បងប្អូនដែលនឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងទាំងអស់ដែលជាគ្រីស្តបរិស័ទ នឹករលឹកដល់ជីវិតដ៏បរិបូរណ៍ ដែលព្រះយេស៊ូប្រទានឲ្យតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ដង្ហើមរបស់ព្រះជាម្ចាស់ ជីវិតរបស់ព្រះជាម្ចាស់ដែលចូលនៅក្នុងខ្លួនរបស់យើង ដើម្បីណែនាំឲ្យយើងទៅជាតែមួយជាមួយព្រះជាម្ចាស់ថែមទៀត។

ព្រះយេស៊ូមានព្រះបន្ទូលថា "**ចូរស្តាប់ខ្ញុំទាំងអស់គ្នា ហើយយល់ឲ្យច្បាស់ថាអ្វីៗដែលពីខាងក្រៅចូលនៅក្នុងមនុស្ស មិនអាចធ្វើឲ្យមនុស្សក្លាយទៅជាមិនបរិសុទ្ធបានឡើយ ផ្ទុយទៅវិញមានតែអ្វីៗដែលចេញពីមនុស្សប៉ុណ្ណោះដែលធ្វើឲ្យមិនបរិសុទ្ធ**"។ តាមរយៈព្រះកាយព្រះគ្រីស្តតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះជាម្ចាស់ណែនាំឲ្យយើងទាំងអស់ជាគ្រីស្តបរិស័ទ ទៅជាមនុស្សដ៏វិសុទ្ធ។ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក នៅពេលនោះព្រះជាម្ចាស់ណែនាំឲ្យយើងទទួលជីវិតរបស់ព្រះអង្គ ដើម្បីឲ្យយើងទៅជាមនុស្សដែលមានលក្ខណៈដូចព្រះអង្គ។ ថ្ងៃនេះដែលយើងទទួលព្រះកាយនិងព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងទៅជាមនុស្សដ៏វិសុទ្ធ ប៉ុន្តែដោយសារយើងផ្ទាល់ខ្លួនយើងបង្កើតអំពើអាក្រក់ អំពើបាបណែនាំឲ្យយើងទៅជាមនុស្សមិនបរិសុទ្ធ។ ព្រះជាម្ចាស់បានបង្កើតយើង ឲ្យទៅជាមនុស្សដែលពោរពេញដោយសេចក្តីស្រឡាញ់។

ទីមួយ អត្ថបទទីពីរ "**ចូរទទួលព្រះបន្ទូលដោយចិត្តស្លូតបូត**" ឲ្យយើងអង្គុយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចិត្តស្លូតបូត។ នេះជាមូលដ្ឋានសម្រាប់យើងជាគ្រីស្តបរិស័ទ ដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីការពារថែរក្សាភាពបរិសុទ្ធដែលយើងបានទទួលពីដើមរៀងមក។ ស្តាប់

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយចិត្តស្លូតបូត ដោយសារព្រះបន្ទូលអាចសង្គ្រោះព្រលឹងបងប្អូន ណែនាំឲ្យយើងទទួលជីវិត ណែនាំឲ្យយើងទទួលកម្លាំង ណែនាំឲ្យយើងទៅជាមនុស្សដ៏ពេញលក្ខណៈ។

ទីពីរ "**ចូរប្រព្រឹត្តតាមព្រះបន្ទូល កុំគ្រាន់តែស្តាប់ទាំងបញ្ឆោតចិត្តខ្លួនឯងប៉ុណ្ណោះឡើយ**" យើងស្តាប់ហើយយើងអនុវត្តតាមព្រះបន្ទូលហ្នឹង។ ពេលព្រះយេស៊ូមានព្រះបន្ទូលថា "**សូមស្រឡាញ់សត្រូវ**" យើងខិតខំស្រឡាញ់សត្រូវ យើងខិតខំធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូ។ កុំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចជាទឹកដែលធ្លាក់លើក្បាលទា ដែលមិនជ្រាបចូលក្បាលវាសោះ កុំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ធ្លាក់លើក្បាលយើងមិនចូល ណែនាំឲ្យជីវិតរបស់យើងនៅដដែលៗ។ ផ្ទុយទៅវិញ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ណែនាំឲ្យយើងយកចិត្តទុកដាក់កែប្រែចិត្តគំនិតគ្រប់ពេលវេលា។

ទីបី "**សូមជួយឧបត្ថម្ភក្មេងកំព្រារ ស្ត្រីមេម៉ាយ ដែលមានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនឲ្យផុតពីអំពើសៅម៉ងរបស់លោកីយ៍នេះ**" យកចិត្តទុកដាក់បម្រើអ្នកតូចតាច។ យើងជាមនុស្សដែលមានទុក្ខលំបាក ប៉ុន្តែនៅមានមនុស្សដែលមានទុក្ខលំបាកជាងយើងច្រើនណាស់ ដូច្នេះយើងធ្វើដូចម្តេច ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ នេះជាមូលហេតុដែលព្រះយេស៊ូរិះគន់គណៈផសារីស៊ី ដែលគោរពតាមវិន័យរបស់សាសនាគេ ប៉ុន្តែគេមិនចេះលើកលែងទោស គេមិនគ្មានចិត្តអាណិតមេត្តាដល់អ្នកក្រីក្រ គេមិនប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ថ្ងៃនេះ ព្រះយេស៊ូណែនាំឲ្យយើងនឹករលឹកដល់ថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ជាថ្ងៃដែលយើងបានទៅជាមនុស្សបរិសុទ្ធ ពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់១០០%។ បើយើងមានសេចក្តីស្រឡាញ់នៅពេញខ្លួនរបស់យើង គ្មានកន្លែងឲ្យអំពើបាបចូល ប៉ុន្តែពេលយើងអស់សេចក្តីស្រឡាញ់ណែនាំឲ្យមានកន្លែងសម្រាប់អំពើបាប។

ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលដើម្បីឲ្យយើងភ្ញាក់ស្មារតី ស្តាប់ព្រះបន្ទូល ប្រព្រឹត្តតាមព្រះបន្ទូល និងស្រឡាញ់អ្នកតូចតាចដោយបម្រើគេជានិច្ច។ យើងអធិដ្ឋានស្តាប់ព្រះបន្ទូល យើងស្រឡាញ់ប្រព្រឹត្តតាមព្រះបន្ទូល បម្រើឲ្យយើងជួយបងប្អូនដែលគ្មានទីពឹង និងណែនាំឲ្យយើងទៅជាមនុស្សបរិសុទ្ធមានន័យថាឲ្យយើងមានលក្ខណៈដូចព្រះជាម្ចាស់។ ពិតមែនព្រះជាម្ចាស់បានបង្កើតយើងឲ្យមានលក្ខណៈដូចព្រះអង្គ មានន័យថាឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណាសម្រាប់បងប្អូនឯទៀតៗ។

យើងអរព្រះគុណព្រះជាម្ចាស់ និងទូលអង្វរព្រះអង្គសូមព្រះអង្គណែនាំឲ្យយើងរស់នៅនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទៅជាមនុស្សថ្មី ដើម្បីបង្កើតសង្គមថ្មី ដោយស្មារដៃរបស់ដែលចេញពីសមត្ថភាពរបស់ព្រះជាម្ចាស់ផ្ទាល់។ អាម៉ែន៕